# ប្រាសាទចតុម្មុខ

ប្រវត្តិវិទូជនជាតិអាមេរិចម្នាក់គឺលោក ម៉ៃឃើល វិឃើរី បានស្នើថា ខ្មែរបានទទួលយកអារ្យធម៌ឥណ្ឌានៅរវាងស.វ.ទី៣នៃគ.ស. ដោយព្រះមហាក្សត្រខ្មែរបានបញ្ជូនទូតទៅរៀនសូត្រនៅស្រុកឥណ្ឌាផ្ទាល់។[១] នៅរវាងពេលនោះហើយដែលឥទ្ធិពលព្រះពុទ្ធសាសនា បានចាប់ផ្ដើមជ្រួតជ្រាបបន្តិចម្ដងៗនៅក្នុងសង្គមខ្មែរ ហើយគេឃើញមានតឹកតាងច្រើននៅរវាងស.វ.ទី៥-៧ ដែលមានច្រើននៅតំបន់អង្គរបុរី ខេត្តតាកែវ។ ព្រះពុទ្ធសាសនាដែលខ្មែរទទួលនៅពេលនោះក៏មានព្រះពុទ្ធសាសនាថេរវាទមកជាមួយដែរ ដ្បិតគេបានរកឃើញរូបព្រះពុទ្ធចូលបរិនិព្វានជាច្រើនជាតឹកតាង។ ប៉ុន្តែឥទ្ធិពលព្រះពុទ្ធសាសនាថេរវាទនេះហាក់ថមថយទៅវិញចាប់ពីស.វ.ទី៧មក ដ្បិតព្រះរាជាខ្មែរទំនងយកព្រហ្មញ្ញសាសនាជាសាសនារបស់រដ្ឋ។ មកដល់ស.វ.ទី១២ និងដើមស.វ.ទី១៣ ក្នុងរជ្ជកាលព្រះបាទធរណិន្ទ្រវរ្ម័ន និងព្រះបាទជ័យវរ្ម័នទី៧ ទ្រង់បានលើកតម្កើងព្រះពុទ្ធសាសនាមហាយានជាសាសនារបស់រដ្ឋវិញ។ នៅពេលនោះ យើងឃើញមានប្រាសាទជាច្រើនសង់ឡើងសម្រាប់ឧទ្ទិសដល់ព្រះពុទ្ធសាសនាមហាយាន។ ក្រោយមកទៀត នៅដើមរជ្ជកាលព្រះបាទស្រិន្ទ្រជ័យវរ្ម័ន ក្នុងរវាងគ.ស.១៣០៧ ទ្រង់ទំនងទទួលព្រះពុទ្ធសាសនាថេរវាទយកជាសាសនារបស់រដ្ឋវិញម្ដង។ គេច្រើនដឹងថា ចាប់ពីពេលនោះមកខ្មែរមិនសូវនិយមកសាងប្រាសាទដូចមុនទៀតទេ ពោល គឺមានតិចតួចខ្លាំងណាស់ ដោយគេប្ដូរមកសង់ជាវត្តអារាមអំពីឈើដែលជាប្រភេទសំណង់ស្រាល សម្រាប់គោរពបូជាដល់សាសនាវិញ។ ប៉ុន្តែការកែលម្អប្រាសាទព្រហ្មញ្ញសាសនាមកជាសាសនដ្ឋានព្រះពុទ្ធសាសនាថេរវាទក៏មានច្រើនផង ហើយខ្លះក៏មានយកថ្មប្រាសាទធ្វើជាខឿនព្រះវិហារក៏មាន។[២]

ក្នុងនោះនៅតំបន់បាកាណ ឬយើងហៅតាមអ្នកស្រាវជ្រាវបារាំងថា "ព្រះខ័នកំពង់ស្វាយ" ក៏មានប្រាសាទមួយដែលទាក់ទងនឹងព្រះពុទ្ធសាសនាថេរវាទនេះដែរ ពោល គឺមានឈ្មោះថា "ប្រាសាទចតុម្មុខ"។ ប៉ុន្តែអ្នកស្រុកតែងហៅប្រាសាទនេះថា "ព្រះអង្គធំ"។ ប្រាសាទនេះ មានទីតាំងនៅភូមិតាសែង ឃុំរណសិរ្ស ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ដែលមានចម្ងាយប្រមាណ ៧០ គីឡូម៉ែត្រពីទីរួមខេត្តព្រះវិហារ និងស្ថិតនៅខាងត្បូងប្រាសាទព្រះស្ទឹងចម្ងាយប្រមាណ ២៩០ម៉ែត្រ។ ប្រាសាទនេះ មានចម្លាក់បដិមាព្រះពុទ្ធអង្គទ្រង់

[១] Vickery 1998.

[២] Thompson 1999.

ឈរធ្វើអំពីថ្មភក់បែរខ្នងទល់គ្នាចំនួន ៤ អង្គ ដែលយើងតែងហៅថា "ព្រះពុទ្ធបដិមាចតុទិស" ហើយមានលក្ខណៈកម្រខ្លាំងណាស់នៅក្នុងសិល្បៈខ្មែរ។ ដ្បិតកន្លែងដទៃទៀតយើងធ្លាប់ឃើញមានតែធ្លាក់នៅលើជញ្ជាំងប្រាសាទឥដ្ឋដូចជា គុកជើង (ប្រាសាទត្នោតជុំ ខេត្តកំពង់ធំ)[៣] និងមួយទៀតចម្លាក់ព្រះពុទ្ធរូបធ្វើអំពីថ្មបាយក្រៀមនៅប្រាសាទភ្នំទេវ (ស្រុកស្វាយលើ ខេត្តសៀមរាប)។ ប៉ុន្តែបើជាថ្មភក់ដូចប្រាសាទចតុម្មុខនេះ គឺមានតែមួយនេះប៉ុណ្ណោះ (រូបលេខ១-២)។

នៅមុនឆ្នាំ២០១៨ ប្រាសាទនេះបានបាក់បែកសល់កម្ពស់ត្រឹមតែជាងមួយម៉ែត្រប៉ុណ្ណោះ តែសព្វថ្ងៃគេបានជួសជុលឡើងវិញដូចដើម (រូបលេខ៣-៤)។ នៅឆ្នាំ២០១៥ លោកបណ្ឌិត ទន់ ពុទ្ធពិសិដ្ឋ ធ្លាប់បានសិក្សាកាយវិការរបស់ព្រះពុទ្ធរូបនៅប្រាសាទចតុម្មុខម្តងរួចមកហើយ។ ក្នុងពេលនោះដោយសាររូបផ្នែកខាងលើបានបាក់បែក មិនទាន់រៀបផ្គុំឡើងវិញ លោកបានសិក្សាតែព្រះហស្តខាងឆ្វេងម្ខាងតែប៉ុណ្ណោះ។ លោកសន្និដ្ឋានថា កាយវិការរបស់ព្រះពុទ្ធអង្គនេះមានទម្រង់បែប"**វិតក្កមុទ្រ**" ពោល គឺបង្ហាញពីម្រាមចង្អុលផ្គុំជាមួយម្រាមមេ រីឯម្រាមផ្សេងទៀតលាទម្លាក់ចុះក្រោម។ លោកបញ្ជាក់ថា កាយវិការនេះមានទម្រង់ដូចព្រះពុទ្ធរូបនៅតំបន់លពបុរី ស្រុកសៀម នាស.វ.ទី១៣។[៤] ប៉ុន្តែបន្ទាប់ពីអ្នកជំនាញរៀបបំណែកទាំងអស់ផ្គុំឡើងវិញកាលពីឆ្នាំ២០១៨រួចមក យើងពិនិត្យមើលទៅកាយវិការព្រះពុទ្ធអង្គទាំងបួនអាចមានទម្រង់បែប "**អភយមុទ្រ**" ដូច្នេះទៅវិញ ពោល គឺព្រះហស្តឆ្វេងដាក់ទម្លាក់ចុះមកក្រោម រីឯព្រះហស្តស្តាំដាក់លាមកមុខត្រឹមដើមទ្រូង (រូបលេខ៥)។ កាយវិការ "**អភយមុទ្រ**" មានន័យថា "***ភាពគ្មានភ័យខ្លាច***"[៥] ហើយជាកាយវិការនៃការធានា និងសុវត្ថិភាពក្នុងការបំបាត់ភាពភ័យខ្លាចរបស់ព្រះពុទ្ធអង្គចំពោះសត្វលោករបស់ទ្រង់។ ទម្រង់កាយវិការបៀបនេះ គឺដូចចម្លាក់ព្រះពុទ្ធអង្គទាំងប្រាំដែលធ្លាក់អំពីឥដ្ឋនៅជញ្ជាំងប្រាសាទគុកជើង (ត្នោតជុំខាងជើង ខេត្តកំពង់ធំ) (រូបលេខ៦)[៦] និងព្រះពុទ្ធអង្គធ្លាក់អំពីថ្មបាយក្រៀមនៅឯប្រាសាទភ្នំទេវដែរ (រូបលេខ៧)។ ចម្លាក់ព្រះពុទ្ធរូបនៅជញ្ជាំងគុកជើង សាងនៅស.វ.ទី១៤ ក្នុងរជ្ជកាលព្រះបាទស្រិន្ទជ័យវរ្ម័ន (គ.ស. ១៣០៧-១៣២៧) ដោយគេសំអាងលើខ្លឹមសារសិលាចារឹកជាភាសាខ្មែរចារនៅលើមេ

---

[៣] Lajonquière 1902: 210; Aymonier 1900: 352; Parmentier 1913:20;ម៉ង់ រ៉ាលី, ២០២១: ២៥៩-២៥៦។

[៤] Puthpiseth Ton 2015: 160.

[៥] Buswell 2013: 2.

[៦] កែវ សូនី, ផុន កសិកា ២០០០: ១៣-២១។

*ទ្វារប្រាសាទ K.144។[៧] ក្រៅពីនេះ ក៏មានចម្លាក់ព្រះពុទ្ធធំៗក្នុងពុទ្ធសាសនាថេរវាទនៅភ្នំសន្ទុក (រូបលេខ២៨) និងភ្នំគូលែន ប៉ុន្តែអាយុកាលអាចក្រោយគុកដើងបន្តិច ពោល គឺនៅរវាងស.វ.ទី១៦។[៨] យើងពិបាកក្នុងការយកអាយុកាលព្រះពុទ្ធផ្សេងៗទាំងនេះ មកធៀបជាមួយចម្លាក់ព្រះពុទ្ធនៅប្រាសាទចតុម្មុខនេះបានឡើយ ដ្បិតវាអាចមានអាយុកាលមុនឬក្រោយផងក៏មិនដឹង។*

*នៅប្រាសាទចតុម្មុខ គេធ្លាប់រកឃើញរូបទេពក្នុងព្រះពុទ្ធសាសនាមួយអង្គក្នុងកាយវិការយកព្រះហស្តទាំងពីរដាក់ឡើងទៅលើ ទ្រថ្មមួយដុំតំណាងឱ្យព្រះធម៌ (រូបលេខ២៩) ហើយនៅលើថ្មនោះមានសិលាចារឹកដែលគេចុះបញ្ជីលេខ K.888។ លោក George Coedès[៩] និងលោកស្រី ពៅ សាវរស[១០] យល់ថាអក្សរចារឹកនេះគេចារជាភាសាបាលី។ ប៉ុន្តែ លោក កំ វណ្ណារ៉ា សិក្សាឡើងវិញនិងស្នើថា អក្សរចារឹកនេះ ចារជាភាសាសំស្ក្រឹត និងភាសាខ្មែរ។[១១] សិលាចារឹកនេះ មានចំនួនបួនបន្ទាត់ដែលរៀបរាប់ថា៖*

*១. នមោ វុទ្ធាយ គុរវេ*

*២. នមោ ធម៌្មាយ តាយណេ*

*៣. នមោ សង្ឃាយ បមាតេ*

*៤. ត្រៃ ... នម. នសមស្ស ....មាន្ត វ្រះកម្រតេងអញ*

*ប្រែសម្រួលថា៖ សូមក្រាបថ្វាយបង្គំចំពោះព្រះពុទ្ធ, សូមក្រាបថ្វាយបង្គំចំពោះព្រះធម៌, សូមក្រាបថ្វាយបង្គំចំពោះព្រះសង្ឃ, សូមក្រាបថ្វាយបង្គំចំពោះព្រះស្រីរតនៈត្រៃទាំងបីមានដល់ព្រះកម្រតេងអញ។[១២]*

*គំនិតគួរពិចារណានោះគឺ ហេតុអ្វីបានជាគេសាងប្រាសាទចតុម្មុខនៅតំបន់នេះ? យើងអាចបកស្រាយដោយពិចារណាថា និងប្រៀបធៀបលក្ខណៈបែបនេះជាមួយទីតាំងបុរាណដ្ឋានដទៃទៀត។ ការសាងសង់ប្រាសាទរបៀបនេះ ទំនងមកពីគេជឿថា នៅតំបន់បាកាណ គឺជាទីក្រុងមួយដ៏សំខាន់ ម៉្លោះហើយត្រូវមានជំនឿលើរឿងចតុម្មុខនេះដូចនៅ*

---

[៧] Coedès, 1964: 34-36.

[៨] Giteau 1975: 132; Boisselier 1966: 280-281.

[៩] Coedès 1966: 211.

[១០] Saveros Pou, 1989: 14.

[១១] *កំ វណ្ណារ៉ា ២០២០: ២៧។*

[១២] *កំ វណ្ណារ៉ា ២០២០: ២៧។*

ក្រុងសំខាន់ៗដូច្នោះដែរ។ ជាក់ស្តែង យើងធ្លាប់ឃើញនៅរាជធានីអង្គរធំ គេសាងប្រាសាទបាយ័ន្តជាកំពូលមានរូបមុខបួន (ចតុម្មុខ) នៅចំកណ្តាលក្រុង។ រីឯនៅអតីតរាជធានីលង្វែក ខេត្តកំពង់ឆ្នាំងសព្វថ្ងៃវិញ មានវត្តមួយឈ្មោះ "**ត្រឡែងកែង**" ដែលនៅទីនោះមានព្រះវិហារមួយសាងឡើងជាទម្រង់ព្រះវិហារត្រឡែងកែង និងបានតម្កល់ព្រះពុទ្ធរូបចតុទិសជាចម្លាក់ទោល។[១៣] ក្រៅពីនេះ យើងឃើញព្រះពុទ្ធបដិមាចតុទិសនៅគុកដើង, ប្រាសាទភ្នំទេវ, ព្រះពុទ្ធបដិមាចតុទិសឆ្លាក់នៅលើថ្មគោលនៃប្រាសាទវត្តនគរ (ស.វ.ទី១៦), ថ្មគោលព្រះពុទ្ធចតុទិសនៅលើខឿននៃព្រះពុទ្ធសាសនាព្រះសិអារ្យ (ខាងត្បូងប្រាសាទបាយ័ន្ត ស.វ.ទី១៨)។ល។ ពោល គឺទំនងមានន័យថាចាប់ពីរវាងចុងស.វ.ទី១២មក គេនិយមគោរព និងសាងសំណង់ជាព្រះពុទ្ធបដិមាចតុទិសនៅក្នុងបរិវេណក្រុង ដូចករណីប្រាសាទចតុម្មុខនេះជាដើម។ ទោះបីជាយ៉ាងណា គំនិតខាងលើនេះគ្រាន់ជាទិន្នន័យពិចារណាបឋមតែប៉ុណ្ណោះ ម៉្លោះហើយយើងត្រូវសិក្សាវែងឆ្ងាយតទៀត។



រូបលេខ១-២៖ ប្រាសាទចតុម្មុខ (រូបថត៖ កុំ វតនៈពិសិដ្ឋ)

[១៣] អ៊ឹង មរកត ២០១៧: ២៦-២៧។



រូបលេខ៣-៤៖ ប្រាសាទចតុម្មុំខមុនពេលជួសជុលផ្គុំថ្មឡើងវិញ (រូបថត៖ កុំ រតនៈពិសិដ្ឋ)



រូបលេខ៥៖ កាយវិការអភយមុទ្រនៃព្រះពុទ្ធអង្គប្រាសាទចតុម្មុំខ (រូបថត៖ កុំ រតនៈពិសិដ្ឋ)



រូបលេខ២៦៖ កាយវិការអភយមុទ្រនៃព្រះពុទ្ធអង្គគុកជើង (រូបថត៖ ផល្លា ផាន)



រូបលេខ២៧៖ ព្រះពុទ្ធអង្គប្រាសាទភ្នំទេវ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៨៖ ព្រះពុទ្ធអង្គចូលបរិនិព្វានឆ្លាក់លើជញ្ជាំងថ្មភ្នំសន្ទុក



បទដោយ៖ ម៉ង់ វ៉ាលី

រូបលេខ៩៖ បដិមាទេពក្នុងព្រះពុទ្ធសាសនាទ្រគម្ពីរ

បញ្ជីឯកសារយោង

កំ វណ្ណារ៉ា
២០២០, "ប្រជុំសិលាចារឹកខេត្តព្រះវិហារ", ភ្នំពេញ
កែវ សុនី, ផុន កសិកា
២០០០, ប្រាសាទត្នោតជុំ, សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យា, ភ្នំពេញ
ម៉ង់ វ៉ាលី
២០២១, "កំពង់ធំ ប្រវត្តិសាស្ត្រ និងប្រាសាទបុរាណ", កំពង់ធំ
អ៊ឹង មរកត
២០១៧, "ពិចារណាលើចម្លាក់ព្រះពុទ្ធបដិមាចតុទិសរវាងស.វ.ទី១៣ និងស.វ.ទី១៦", សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យា, ភ្នំពេញ

**Asley, Thompson**
1999, *Mémoires du Cambodge*, Université de Vol II, Paris
**Aymonier, Etienne**
1900, *"Le Cambodge"*, *Tome I, Le royume actuel*, Paris.
**Boisselier, Jean**
1966, "*Asie du Sud-Est, Le Cambodge* ", Tome I, Paris
**Buswell, Robert Jr.,**
2013, *"Princeton dictionary of Buddhism",* Princeton Univeristy
**Coedès, George**
1964, *Inscription du Cambodge*, Vol VII, Hanoi
1966, *Inscription du Cambodge,* Vol VIII, Paris
**Giteau, Madelein**
1975, *Iconographie du Cambodge post-Angkorian*, Paris
**Lunet De Lajonquière**
1902, *Inventaire descriptive des monuments du Cambodge*, Tome I, Paris
**Parmentier, Henri**
1913, "Complément l'iventaire descriptive des monuments du Cambodge", *BEFEO*, Tome 13, Paris
**Saveros Pou**
1992, *Dictionnaire Vieux Khmer-Français-Englais*, Paris
**Tun, Puthpiseth**
2015, *Bouddhisme Therava et production artistique en pays khmer : Etude dúne corpus d'images en ronde-bosse du Buddha (XIIe – XVI siècles)*, Thèse de doctorat, Unveristy Paris-Sorbornne, Paris
**Vickery, Michael**
1998, *Society, Economic and Politics in pre-Angkor Cambodia, 7th - 8th centuries*, Tokyo.